ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០២.សរ.ណន

សារាចរណែនាំ

ស្តីពី

ការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ និងប្រើប្រាស់ជាក់ស្តែង នៅតំបន់វាលទំនាបដែលលិចទឹកក្នុងរដូវដំឡើង នៃដែនដីដែលទទួលរងបរទឹកទន្លេមេគង្គ

កន្លងមក រាជរដ្ឋាភិបាលបាននិងកំពុងខិតខំអនុវត្តយ៉ាងមុតមាំនូវដំណើរការចុះបញ្ជីដីធ្លី និងការចេញបណ្ណកម្មសិទ្ធិលើដីធ្លីជូនប្រជាពលរដ្ឋទូទៅនៅទូទាំងប្រទេស ។ ទន្ទឹមនឹងនេះ ការវិវឌ្ឍសង្គមនិងការអភិវឌ្ឍដីធ្លីបានធ្វើឲ្យមានការប្រែប្រួលដល់វិសាលភាពនៃដែននេសាទដែលត្រូវបានកំណត់តាំងពីយូរយារណាស់មកហើយ ដោយបច្ចុប្បន្ននៅតំបន់វាលទំនាបដែលលិចទឹកក្នុងរដូវដំឡើង មានលំនៅឋាន វត្តអារាម និងស្រែចម្ការរបស់ប្រជាពលរដ្ឋមួយចំនួនតាំងនៅ ។ ប្រការនេះ ធ្វើឲ្យមានភាពមិនច្បាស់លាស់ក្នុងការកំណត់សិទ្ធិលើដីធ្លីរបស់ប្រជាពលរដ្ឋ ក្នុងតំបន់ដែលទទួលរងបរទឹកទន្លេមេគង្គ ពិសេសតំបន់វាលទំនាបដែលលិចទឹកក្នុងរដូវដំឡើង ហើយដែលប្រជាពលរដ្ឋបាននិងកំពុងកាន់កាប់និងបង្កបង្កើនផលនារដូវសម្រាក ។

ក្នុងន័យនេះ ក្នុងគោលដៅធានាសិទ្ធិលើដីធ្លីរបស់ប្រជាពលរដ្ឋ រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ការជំរុញផលិតកម្មកសិកម្ម និងការធានាសន្តិសុខសង្គម រាជរដ្ឋាភិបាលធ្វើការណែនាំដល់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ផ្នែក គ្រប់ថ្នាក់ ដូចតទៅ ៖

១. ត្រូវចុះបញ្ជី និងផ្តល់បណ្ណកម្មសិទ្ធិលើដីធ្លី ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនារដូវសម្រាក នៅតំបន់វាលទំនាបដែលលិចទឹកក្នុងរដូវដំឡើងនៃដែនដីដែលទទួលរងបរទឹកទន្លេមេគង្គ ។ ប៉ុន្តែករណីនេះ បិនអនុវត្តចំពោះតំបន់ទំនាបដែលលិចទឹកនៅជុំវិញបឹងទន្លេសាប រហូតមកដល់ព្រំប្រទល់ខេត្តកណ្តាល ។

២. ប្រជាពលរដ្ឋក្នុងតំបន់វាលទំនាបលិចទឹកក្នុងរដូវដំឡើង ដែលបានទទួលបណ្ណកម្មសិទ្ធិ ត្រូវប្រើប្រាស់អាស្រ័យផល និងចាត់ចែងដីជាកម្មសិទ្ធិរបស់ខ្លួន ឲ្យស្របតាមវិធានដីក្នុងទំហំដែលច្បាប់បានកម្រិត ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ផ្នែក គ្រប់ថ្នាក់ ត្រូវចាត់ចែងផ្សព្វផ្សាយឲ្យបានទូលំទូលាយ និងចូលរួមសហការអនុវត្តតាមសមត្ថកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃ ២៧ ខែមីនា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ចម្លងជូន៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ធកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ធកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ